# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង លើគំរោងធ្វើអាជីវកម្មរ៉ែដែក
# របស់ក្រុមហ៊ុន HOANG ANH-RATTANAKIRI CO., LTD.




Draft

ទីតាំង: តំបន់ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី

រៀបចំដោយ: ក្រុមហ៊ុន ស៊ី អ៊ី អេស

ខែកក្កដា ឆ្នាំ២០១១

Draft

EW64

# មាតិកា


សេចក្ដីសង្ខេប.....I

**ជំពូកទី០១: សេចក្ដីផ្ដើម**.....1

១.១. លក្ខណៈទូទៅនៃគំរោង.....2

១.២. គោលបំណងនៃការរៀបចំរបាយការណ៍.....3

១.៣. វិធីសាស្ត្រ និងទំហំនៃការសិក្សា.....4

១.៣.១. ការសិក្សាទៅលើធនធានបរិស្ថាន-សង្គមដែលមានស្រាប់ក្នុងតំបន់គំរោង.....4

១.៣.២. ការវិភាគហេតុប៉ះពាល់បរិស្ថាន និងការជ្រើសរើសវិធានការកាត់បន្ថយ.....6

១.៣.៣. ការរៀបចំរបាយការណ៍.....7

**ជំពូកទី០២: ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធ**.....8

២.១. ច្បាប់ពាក់ព័ន្ធ.....9

២.១.១. ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ.....9

២.១.២. ច្បាប់ស្ដីពីព្រៃឈើ.....9

២.១.៣. ច្បាប់ស្ដីពីជលផល.....10

២.១.៤. ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ.....11

២.១.៥. ច្បាប់ភូមិបាល.....12

២.១.៦. ច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក.....13

២.១.៧. ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា.....13

២.១.៨. ច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ.....14

២.២. អនុក្រឹត្យពាក់ព័ន្ធ.....17

២.២.១. អនុក្រឹត្យស្ដីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន.....17

២.២.២. អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលទឹក.....17

២.២.៣. អនុក្រឹត្យស្ដីពីការគ្រប់គ្រងសំណល់រឹង.....17

២.២.៤. អនុក្រឹត្យស្ដីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ.....18


Draft

**ជំពូកទី០៣: ការពិពណ៌នាអំពីគំរោង** ....... 19
៣.១. ធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងខេត្តរតនគិរី ....... 20
៣.២. ការលើកទឹកចិត្តឱ្យមានការសិក្សាស្រាវជ្រាវរុករករ៉ែ និងការធ្វើអាជីវកម្មរ៉ែ ....... 20
៣.៣. សាវតាក្រុមហ៊ុន និងគំរោង ....... 21
៣.៣.១. សាវតាក្រុមហ៊ុន ....... 21
៣.៣.២. សាវតាគំរោង ....... 21
៣.៤. ការវិនិយោគទៅលើការធ្វើអាជីវកម្មរ៉ែ និងគោលបំណង ....... 23
៣.៥. ទីតាំងក្រុមហ៊ុន និងគំរោងធ្វើអាជីវកម្ម ....... 24
៣.៦. លិខិតគោលការណ៍ច្បាប់អនុញ្ញាតដែលពាក់ព័ន្ធ ....... 24
៣.៧. សកម្មភាពអាជីវកម្ម ....... 27
៣.៧.១. ការបែងចែក និងការប្រើប្រាស់ដីនៅក្នុងទីតាំងគំរោង ....... 27
៣.៧.២. មធ្យោបាយអាជីវកម្ម ....... 28
៣.៨. សកម្មភាព និងខ្សែសង្វាក់អាជីវកម្ម ....... 33
៣.៩. ការវិភាគអំពីស្ថានភាពសេដ្ឋកិច្ចរបស់គំរោង ....... 46
៣.៩.១. ទុនវិនិយោគ និងលំហូរសាច់ប្រាក់ ....... 46
៣.៩.២. ប្រសិទ្ធិភាពសេដ្ឋកិច្ច ....... 47

**ជំពូកទី០៤: ការពិពណ៌នាអំពីធនធានបរិស្ថានដែលមានស្រាប់** ....... 48
៤.១. ធនធានរូបសាស្ត្រ ....... 49
៤.១.១. លក្ខណៈទូទៅនៃភូគព្ភសាស្ត្រ និងសណ្ឋានដី/ឋានលេខា ....... 49
៤.១.២. អាកាសធាតុ ....... 56
៤.១.៣. ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើអាកាសធាតុនៅក្នុងប្រទេស ....... 62
៤.១.៤. គុណភាពខ្យល់ ....... 62
៤.១.៥. សំលេង-រំញ័រ ....... 63
៤.១.៦. ប្រព័ន្ធផ្លូវទឹក និងគុណភាពទឹក ....... 63
៤.២. ធនធានជីវសាស្ត្រ ....... 73
៤.២.១. ព្រៃឈើ ....... 73

Draft

៤.២.២. សត្វលើគោក/សត្វព្រៃ ....................................................................................... 88

៤.២.៣. សត្វក្នុងទឹក/មច្ឆាជាតិ ....................................................................................... 92

៤.២.៤. ប្រព័ន្ធអេកូឡូស៊ី ....................................................................................... 93

៤.៣. ធនធានសេដ្ឋកិច្ច-សង្គម ....................................................................................... 94

៤.៣.១. ប្រជាសាស្ត្រ និងការតាំងទីលំនៅ ....................................................................................... 94

៤.៣.២. ស្ថានភាពសេដ្ឋកិច្ច ....................................................................................... 97

៤.៣.៣. ការប្រើប្រាស់ដី ....................................................................................... 99

៤.៣.៤. ការប្រើប្រាស់ទឹក ....................................................................................... 100

៤.៣.៥. ការប្រើប្រាស់ថាមពល ....................................................................................... 105

៤.៣.៦. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម ....................................................................................... 105

៤.៣.៧. ការអប់រំ ....................................................................................... 105

៤.៣.៨. សុខភាព និងសុខមាលភាពសាធារណៈ ....................................................................................... 110

៤.៣.៩. សម្បត្តិវប្បធម៌ ....................................................................................... 111

៤.៣.១០. តំបន់ទេសចរណ៍ ....................................................................................... 112

៤.៣.១១. ពត៌មានអំពីភាពក្រីក្រ ....................................................................................... 112

**ជំពូកទី០៥: ការចូលរួមពីសាធារណៈជន** ....................................................................................... 115

៥.១. សេចក្តីផ្តើម ....................................................................................... 116

៥.២. ការចូលរួមរបស់សាធារណៈជន ....................................................................................... 116

៥.២.១. ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុកបរកែវ ....................................... 116

៥.២.២. ការផ្សព្វផ្សាយអំពីគំរោង និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុកអូរយ៉ាដាវ ....................................... 124

៥.២.៣. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ....................................... 130

៥.២.៤. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរបរិស្ថានខេត្ត ....................................... 132

៥.២.៥. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរកសិកម្មខេត្ត ....................................... 133

៥.២.៦. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយខ័ណ្ឌព្រៃឈើខេត្ត ....................................... 135

៥.២.៧. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយសង្កាត់រដ្ឋបាលជលផលខេត្ត ....................................... 136

៥.២.៨. ការស្ទង់មតិ និងពិគ្រោះយោបល់ជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ....................................... 137


Draft

៥.៣. មតិយោបល់ និងការបកស្រាយរបស់ក្រុមហ៊ុន......138
៥.៤. សន្និដ្ឋាន......140

**ជំពូកទី០៦: ការប៉ះពាល់បរិស្ថាន-សង្គម និងវិធានការកាត់បន្ថយ**......144
៦.១. សក្តានុពលនៃការប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ......145
៦.១.១. ដំណាក់កាលមុនប្រតិបត្តិគំរោង......145
៦.១.២. ដំណាក់កាលប្រតិបត្តិគំរោង......150
៦.១.៣. ដំណាក់កាលបញ្ចប់គំរោង......158
៦.២. សក្តានុពលនៃការប៉ះពាល់វិជ្ជមាន......160
៦.២.១. ធនធានព្រៃឈើ......160
៦.២.២. ចំណូលថវិកាជាតិ......160
៦.២.៣. ការប្រើប្រាស់ដី......161
៦.២.៤. ហេដ្ឋារចនាសម្ព័ន្ធជនបទ......161
៦.២.៥. មុខរបរ និងប្រាក់ចំណូល......161

**ជំពូកទី០៧: ផែនការគ្រប់គ្រងបរិស្ថាន-សង្គម**......162
៧.១. សេចក្តីផ្តើម......163
៧.២. ការសង្ខេបពីហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ......163
៧.៣. កម្មវិធីបណ្តុះបណ្តាល......164
៧.៤ កម្មវិធីត្រួតពិនិត្យបរិសាន......165
៧.៤.២. ស្ថាប័នទទួលខុសត្រូវក្នុងការអង្កេតតាមដាន និងត្រួតពិនិត្យបរិស្ថាន......165
៧.៤.៣. របាយការណ៍ត្រួតពិនិត្យបរិស្ថាន......166
៧.៤.៤ កម្មវិធី និងខួបនៃការត្រួតពិនិត្យបរិស្ថាន......166
៧.៥. ផែនការថវិកាសំរាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន......173
៧.៥.១ មូលនិធិបរិស្ថាន......175
៧.៥.២ មូលនិធិសង្គម......175

Draft

**ជំពូកទី ៨: សេចក្តីសន្និដ្ឋាន និងអនុសាសន៍**......178
៨.១. សេចក្តីសន្និដ្ឋាន......179
៨.២. អនុសាសន៍......180
**ឯកសារយោង**......182

**ឧបសម្ព័ន្ធ១**......185
**ឧបសម្ព័ន្ធ២**......210
**ឧបសម្ព័ន៣**......236
**ឧបសម្ព័ន៤**......241
**ឧបសម្ព័ន៥**......251
**ឧបសម្ព័ន៦**......320

Draft

# បញ្ជីតារាង


តារាង 01 : ចំណុចនិយាមកាទីតាំងសិក្សាស្រាវជ្រាវរុករករ៉ែ.......21

តារាង 02 : ចំណុចនិយាមកាទីតាំងជីកយកល្បាយអាចម៍រ៉ែ.......22

តារាង 03 : ចំណុចនិយាមការបស់ព្រំប្រទល់ទីតាំងគំរោង.......24

តារាង 04 : ការបែងចែក និងការប្រើប្រាស់ដីនៅក្នុងទីតាំងគំរោង.......27

តារាង 05 : គំរោងចំណាយវិនិយោគសរុប.......28

តារាង 06 : គំរោងចំណាយសំរាប់ការទិញឧបករណ៍ និងសំភារៈបរិក្ខារអាជីវកម្ម.......30

តារាង 07 : ការចំណាយសំរាប់ហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ស៊ីវិល.......31

តារាង 08 : ការចំណាយសំរាប់មធ្យោបាយដឹកជញ្ជូន.......32

តារាង 09 : ការចំណាយសំរាប់សំភារៈការិយាល័យ និងគ្រឿងសង្ហារឹម.......32

តារាង 10 : តំរូវការកំលាំងពលកម្ម.......33

តារាង 11 : តំរូវការផ្សេងៗ.......33

តារាង 12 : សកម្មភាព និងខ្សែសង្វាក់អាជីវកម្ម.......34

តារាង 13 : ចំណាត់ថ្នាក់នៃតំបន់ធម្មជាតិ និងភាពស្របគ្នាជាមួយនឹងខេត្ត/ក្រុងនៅក្នុងប្រទេស.......50

តារាង 14 : គុណភាពទឹកនៅក្នុងអូរកប និងស្តង់ដាគុណភាពទឹកជាតិ.......67

តារាង 15 : គុណភាពទឹកនៅក្នុងអូរប៉ុក និងស្តង់ដាគុណភាពទឹកជាតិ.......68

តារាង 16 : គុណភាពទឹកនៅក្នុងអណ្តូងច្របនៅក្នុងភូមិប្រឡេ និងស្តង់ដាគុណភាពទឹកជាតិ.......70

តារាង 17 : គុណភាពទឹកនៅក្នុងអណ្តូងច្របនៅក្នុងភូមិក្រៀល និងស្តង់ដាគុណភាពទឹកជាតិ.......71

តារាង 18 : ប្រភេទរុក្ខជាតិ ដែលបានជួបប្រទះនៅក្នុងកំឡុងពេលសិក្សា.......81

តារាង 19 : ដង់ស៊ីតេ (ដ./ហ.ត.) និងមាឌឈើឈរ (ម.$^3$/ហ.ត.) ទៅតាមចំណាត់ថ្នាក់អង្កត់ផ្ចិត និងឈើពាណិជ្ជកម្ម.......85

តារាង 20 : មាឌឈើសរុប (ម.$^3$/ហ.ត.) និងសមាសភាគ (%) និងគុណភាពឈើទៅតាមចំណាត់ថ្នាក់អង្កត់ផ្ចិតនីមួយៗ.......87

តារាង 21 : វត្តមានថនិកសត្វ ដែលធ្លាប់បានជួបប្រទះនៅក្នុងតំបន់គំរោង.......89

តារាង 22 : វត្តមានឧរង្គសត្វ ដែលធ្លាប់បានជួបប្រទះនៅក្នុងតំបន់គំរោង.......90


Draft

តារាង 23 : វត្តមានសត្វស្លាប ដែលធ្លាប់ជួបប្រទះនៅក្នុងតំបន់គំរោង....................90

តារាង 24 : វត្តមានមច្ឆជាតិ និងសត្វក្នុងទឹក ដែលធ្លាប់បានជួបប្រទះនៅក្នុងតំបន់គំរោង....................92

តារាង 25 : ឈ្មោះឃុំ និងភូមិ ដែលពាក់ព័ន្ធនឹងតំបន់គំរោង....................96

តារាង 26 : ស្ថានភាពមុខរបររបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គំរោង....................97

តារាង 27 : ស្ថានភាពបង្កបង្កើនផលរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងនៅឆ្នាំ2009....................98

តារាង 28 : ការប្រើប្រាស់ដីកសិកម្មនៅក្នុងឃុំកិចុង ឃុំកក់ ឃុំលំជ័រ និងឃុំសោមធំ....................100

តារាង 29 : ស្ថានភាពប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម (ឆ្នាំ2010)....................106

តារាង 30 : ហេដ្ឋារចនាសម្ព័ន្ធសំរាប់វិស័យអប់រំនៅក្នុងឃុំទាំងបួន....................108

តារាង 31 : ស្ថិតិប្រជាពលរដ្ឋ ដែលមានទឹកស្អាតទទួលទាន និងមានបង្គន់អនាម័យប្រើប្រាស់....................111

តារាង 32 : របាយជនជាតិដើមភាគតិចនៅក្នុងតំបន់ឃុំកិចុង ឃុំកក់ ឃុំលំជ័រ និងឃុំសោមធំ....................111

តារាង 33 : ផែនការ និងសកម្មភាពអភិវឌ្ឍន៍សហគមន៍មូលដ្ឋានរបស់ក្រុមហ៊ុន....................177


Draft

# បញ្ជីរូបភាព


រូបភាព 01 : ផែនទីទីតាំងគំរោង..........26

រូបភាព 02a : គំនូសបំព្រួញបង្ហាញអំពីសកម្មភាព និងខ្សែសង្វាក់អាជីវកម្ម..........39

រូបភាព 02b : គំនូសបំព្រួញបង្ហាញអំពីវដ្ត និងសកម្មភាពចំរាញ់ល្បាយអាចម៍រ៉ែ..........40

រូបភាព 02c : គំនូសបំព្រួញបង្ហាញអំពីសកម្មភាព និងខ្សែសង្វាក់អាជីវកម្ម..........41

រូបភាព 03 : គំនូសបំព្រួញបង្ហាញអំពីឧបករណ៍ គ្រឿងចក្រ និងគ្រឿងយន្តប្រើប្រាស់នៅក្នុងគំរោង..........45

រូបភាព 04 : ផែនទីបង្ហាញអំពីស្ថានភាពភូគព្ភសាស្ត្រ និងសណ្ឋានដី/ឋានលេខានៃព្រះរាជាណាចក្រកម្ពុជា......49

រូបភាព 05 : ផែនទីបង្ហាញអំពីរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងស្រុកបរកែវ ខេត្តរតនគិរី..........51

រូបភាព 06 : ផែនទីបង្ហាញអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិនៅក្នុងស្រុកបរកែវ ខេត្តរតនគិរី..........52

រូបភាព 07 : ផែនទីបង្ហាញអំពីរដ្ឋបាល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី..........53

រូបភាព 08 : ផែនទីបង្ហាញអំពីការប្រើប្រាស់ដី និងធនធានធម្មជាតិនៅក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី..........54

រូបភាព 09 : ផែនទីបង្ហាញអំពីស្ថានភាពភូគព្ភសាស្ត្រ និងសណ្ឋានដី/ឋានលេខានៃតំបន់គំរោង..........55

រូបភាព 10 : ផែនទីបង្ហាញអំពីប្រភេទដីនៅក្នុងទីតាំងគំរោង..........57

រូបភាព 11 : សីតុណ្ហភាពនៅក្នុងតំបន់គំរោង..........58

រូបភាព 12 : ក៏រិតសីតុណ្ហភាពនៅក្នុងខេត្តរតនគិរី (ដែលទីតាំងគំរោងស្ថិតនៅ) ប្រចាំឆ្នាំ2003–2009..........59

រូបភាព 13 : ក៏រិតកំពស់ទឹកភ្លៀងនៅក្នុងខេត្តរតនគិរី (ដែលទីតាំងគំរោងស្ថិតនៅ) ប្រចាំឆ្នាំ1998–2009.......61

រូបភាព 14 : ក៏រិតទឹកភ្លៀងនៅក្នុងតំបន់គំរោង (Data Sources: FAO 2003)..........61

រូបភាព 15 : ផែនទីបង្ហាញអំពីប្រព័ន្ធផ្លូវទឹកនៅក្នុងតំបន់គំរោង និងទីតាំងយកសំណាកទឹកនៅក្នុងអូរកប អូរប៉ុក និងទឹកអណ្តូងច្រប ដែលមានទីតាំងនៅក្នុងភូមិគ្រៀល និងភូមិប្រឡេ..........66

រូបភាព 16 : ផែនទីគំរបព្រៃនៅក្នុងតំបន់ និងទីតាំងគំរោង (រដ្ឋបាលព្រៃឈើ2006)..........74

រូបភាព 17 : ផ្ទៃដីប្រភេទព្រៃនៅក្នុងទីតាំងគំរោង (ផែនទីគំរបឆ្នាំ2006)..........75

រូបភាព 18 : ទិដ្ឋភាពទូទៅនៅក្នុងទីតាំងគំរោង (កាប់ឈើរានព្រៃធ្វើស្រែ-ចំការ) ដែលបានជួបប្រទះ នៅពេលសិក្សា..........77

រូបភាព 19 : ផែនទីបង្ហាញអំពីទីតាំងឡូតិ៍គំរូ ដែលបានជ្រើសរើសដោយចៃដន្យ..........78

រូបភាព 20 : ស្ថានភាព និងប្រភេទរុក្ខជាតិ ដែលបានជួបប្រទះនៅក្នុងកំឡុងពេលសិក្សា..........79

រូបភាព 21 : ផែនទីរដ្ឋបាលបង្ហាញអំពីភូមិ-ឃុំ ដែលនៅក្បែរ និងនៅក្នុងតំបន់គំរោង..........95


Draft

រូបភាព 22 : ស្ថិតិចំនួនប្រជាពលរដ្ឋ នៅក្នុងឃុំដែលពាក់ព័ន្ធនឹងគំរោងក្នុងកំឡុងឆ្នាំ2007–2009 ..................96

រូបភាព 23 : ស្ថិតិចំនួនប្រជាពលរដ្ឋ នៅក្នុងភូមិដែលពាក់ព័ន្ធនឹងគំរោង..........................................97

រូបភាព 24 : វដ្តនៃការប្រកបរបររបស់ប្រជាពលរដ្ឋក្នុង01ឆ្នាំ..........................................100

រូបភាព 25 : ផែនទីបង្ហាញអំពីទីតាំងដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងទីតាំងគំរោង.............102

រូបភាព 26 : អត្រាអ្នកមិនចេះអក្សរដែលមានអាយុ15–60ឆ្នាំ នៅក្នុងឃុំកិចុង ឃុំកក់ ឃុំលំជ័រ និង ឃុំសោមគល់..........................................107

រូបភាព 27 : ស្ថិតិកុមារ ( អាយុ06–14ឆ្នាំ) នៅក្នុងឃុំកិចុង ឃុំកក់ ឃុំលំជ័រ និងឃុំសោមធំ ដែលបាន ចូលរៀន..........................................109

រូបភាព 28 : ស្ថានភាពការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងតំបន់ គំរោង..........................................113

រូបភាព 29 : ការផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន..........141

រូបភាព 30 : កិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញ និងមន្ទីរពាក់ព័ន្ធ ........................143


Draft

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ 01 : លិខិតគោលការណ៍ច្បាប់.....185
ឧបសម្ព័ន្ធ 02 : កន្លែងជីកយកល្បាយអាចម៍រ៉ែ.....210
ឧបសម្ព័ន្ធ 03 : លទ្ធផលវិភាគគុណភាពទឹក.....236
ឧបសម្ព័ន្ធ 04 : វិធីសាស្ត្រលំអិតនៃការធ្វើសារពើភ័ណ្ឌព្រៃឈើ.....241
ឧបសម្ព័ន្ធ 05 : ស្ថិតិដីស្រែ-ចំការដែលប៉ះពាល់ និងដំណោះស្រាយ.....251
ឧបសម្ព័ន្ធ០៦ : បញ្ជីរាយនាមឈ្មោះនិងលេខទូស័ព្ទស្ថាប័នដែលពាក់ព័ន្ធក្នុងតំណាក់កាលសិក្សាគំរោង.....320

Draft

# សេចក្តីសង្ខេប

## ១.សេចក្តីផ្តើម

ការសិក្សាអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គមដំបូងលើគំរោងអភិវឌ្ឍន៍ធ្វើអាជីវកម្មរ៉ែដែកនេះ មានគោលបំណងដើម្បីៈ (i) ពិនិត្យឡើងវិញ និងពិភាក្សាអំពីក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ (ii) សិក្សាលើធនធានបរិស្ថានដែលមានស្រាប់ដូចជា ធនធានជីវសាស្ត្រ រូបសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម (iii) វិភាគពីការប៉ះពាល់បរិស្ថាន-សង្គមនានា (iv) រិះរកនូវវិធានការកាត់បន្ថយ និងរៀបចំជាផែនការគ្រប់គ្រងបរិស្ថាន-សង្គមសមស្រប និង (v) ធ្វើការសន្និដ្ឋានរួមអំពីផលប្រយោជន៍នៃវត្តមានគំរោង ធៀបជាមួយនឹងការទុកទីតាំងគំរោងឱ្យស្ថិតនៅក្នុងស្ថានភាពដូចពេលបច្ចុប្បន្ន។

វិធីសាស្ត្រនៃការសិក្សានេះរួមមានៈ (i) ការប្រមូលទិន្នន័យមានស្រាប់ពីក្រសួង-ស្ថាប័ន វិទ្យាស្ថានស្រាវជ្រាវ អាជ្ញាធរដែនដីដែលពាក់ព័ន្ធជាដើម (ii) ការប្រមូលទិន្នន័យគោល តាមរយៈការចុះសង្កេតផ្ទាល់ ការសំភាសន៏-ពិគ្រោះយោបល់ជាលក្ខណៈបុគ្គល-ក្រុមគោលដៅ ការធ្វើសារពើភ័ណ្ឌព្រៃឈើ និងការយកសំណាកទឹកមកវិភាគ និង (iii) ការវិភាគអំពីការប៉ះពាល់បរិស្ថាន-សង្គមដោយប្រើប្រាស់ Checklist, Matrix, Overlay & Geographic Information System (GIS), Expert System និង Professional Judgement និងការជ្រើសរើសវិធានការកាត់បន្ថយដោយផ្អែកតាមគោលការណ៍ណែនាំរបស់សមាគមន៍អន្តរជាតិស្តីពីការវាយតំលៃផលប៉ះពាល់ (International Association for Impact Assessment, IAIA)។

Draft

## ២. ក្របខ័ណ្ឌច្បាប់

ការសិក្សាបានបង្ហាញឱ្យឃើញថា ច្បាប់សំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងគំរោងនេះរួមមានៈ (i) ច្បាប់ស្តីពីកិច្ច-ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ii) ច្បាប់ស្តីពីព្រៃឈើ (iii) ច្បាប់ស្តីពីជលផល (iv) ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (v) ច្បាប់ភូមិបាល (vi) ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (V) ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (vi) ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (vii) អនុក្រឹត្យស្តីពីកិច្ចដំណើរវាយតំលៃហេតុប៉ះពាល់បរិស្ថាន (viii) អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក (iv) អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (x) អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (xi) អនុក្រឹត្យស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (xii) អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និង (xiii) ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ។

## ៣. ការពិពណ៌នាពីគម្រោង

ក្រុមហ៊ុន Hoang Ahn Rattanakiri Co., Ltd. ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងមានដើមទុនចំនួន64.000.000.000រៀល (US$16.000.000)។ ក្រុមហ៊ុននេះបានទទួលសម្បទានដីនៅក្នុងតំបន់ស្រុកបរកែវ និងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ពីរាជរដ្ឋាភិបាលក្នុងទំហំ 154គ.ម$^2$ ដើម្បីធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែ ហើយដោយសារតំបន់នេះមានសក្តានុពលធនធានរ៉ែដែលអាចធ្វើ

អាជីវកម្មបាន ក្រុមហ៊ុនបានស្នើសុំទៅរាជរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងវិស័យរ៉ែ ដើម្បីបន្តដំណើរការគំរោងសិក្សាស្រាវជ្រាវរុករករ៉ែទៅជាការធ្វើអាជីវកម្មរ៉ែដែកលើផ្ទៃដីទំហំ260ហតវិញ (ទំហំផ្ទៃដីកាយយករ៉ែត្រឹមតែ 32.60ហត) សំរាប់ក្នុងរយៈពេល09.50ឆ្នាំ។ ដើម្បីដំណើរការគំរោង ក្រុមហ៊ុនត្រូវការកែលំអ រៀបចំ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា ការបាញ់ ថ្នាំក្រហមកំណត់ព្រំដី ប្រព័ន្ធផ្លូវថ្នល់នានា ទីស្នាក់ការ កន្លែងស្នាក់នៅការដ្ឋាន រោងចក្រ រោងជាង អាហារដ្ឋាន ស្ថានីយ៍ទឹកស្អាត និងប៉មយាមជាដើម ក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង។ នៅក្នុងដំណាក់កាលប្រតិបត្តិគំរោង ក្រុមហ៊ុនត្រូវឈូសសំអាតគំរបព្រៃ ដំណើរការជិកយកល្បាយអាចម៍រ៉ែ ការដឹកជញ្ជូន ការចំរាញ់យករ៉ែដែក និងការ សាងសង់ទីលានចាក់សំណល់ដី-ថ្មជាដើម។

## ៤. ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

ធនធានរូបសាស្ត្របរិស្ថាន បានសិក្សាផ្តោតសំខាន់ទៅលើលក្ខណៈទូទៅនៃដី អាកាសធាតុ និងប្រព័ន្ធផ្លូវទឹក។ ទីតាំងគំរោង គឺស្ថិតនៅក្នុងតំបន់ខ្ពង់រាបលាយឡំនឹងកូនភ្នំដោយកន្លែង និងមានរយៈកំពស់ចន្លោះប្រមាណពី172–328 ម. ធៀបនឹងនីវ៉ូទឹកសមុទ្រ និងមានដី01ប្រភេទ (Latosols)។ សីតុណ្ហភាពនៅក្នុងតំបន់គំរោងជាមធ្យមប្រចាំឆ្នាំស្ថិតនៅក្នុងចន្លោះ27,10–28,55អង្សាសេ ហើយកំពស់ទឹកភ្លៀងប្រចាំឆ្នាំស្ថិតនៅក្នុងចន្លោះ1.600–2.800ម.ម.។ ដោយសារតំបន់នេះមិនទាន់មានសកម្មភាពអភិវឌ្ឍន៍ផ្នែកឧស្សាហកម្មខ្លាំងក្លានៅឡើយ ដូច្នេះការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ ពុំមែនជាបញ្ហាសំខាន់គួរឱ្យកត់សំគាល់នោះទេ។ ជាមួយគ្នានេះដែរ ទីតាំងគំរោងមានប្រព័ន្ធផ្លូវទឹកមួយចំនួនដូចជា អូរកប អូរចង្ហារ និងដៃរបស់អូរនេះមួយចំនួន ប៉ុន្តែប្រព័ន្ធផ្លូវទឹកទាំងនេះភាគច្រើនទទួលនូវការគោករាំងស្ងួតស្ទើរតែទាំងស្រុងនៅក្នុងរដូវប្រាំង លើកលែងតែអូរកប៉ុណ្ណោះដែលនៅមានទឹកតិចតួចសូម្បីតែនៅក្នុងរដូវប្រាំង។ ការវិភាគទឹកនៅក្នុងអូរ (ទឹកអូរកប អូរប៉ុក) និងទឹកអណ្តូងច្រប់ (នៅក្នុងភូមិក្រៀល និងភូមិប្រឡោ) បង្ហាញឱ្យឃើញថា គុណភាពទឹក (pH, Total Hardness, Fe, AS, Pb និង Hg ជាដើម) ស្ថិតនៅក្នុងកំរិតស្តង់ដាទឹកផឹកជាតិ លើកលែងតែ Turbidity, Total Coliform និង E-Coli ដែលមានកំរិតលើសពីស្តង់ដា។

ធនធានជីវសាស្ត្រ បានសិក្សាផ្តោតសំខាន់ទៅលើធនធានព្រៃឈើ សត្វព្រៃ មច្ឆាជាតិ និងប្រព័ន្ធអេកូឡូស៊ី។ ព្រៃឈើនៅក្នុងទីតាំងគំរោងគ្របដណ្តប់ដោយព្រៃស្រោង (Evergreen Forest = 1.252ហ.ត. = 25,75% នៃផ្ទៃដីគំរោងសរុប) និងបន្ទាប់មកព្រៃពាក់កណ្តាលស្រោង (Semi Evergreen Forest = 1.826ហ.ត. = 37,56% នៃផ្ទៃដីគំរោងសរុប) ព្រៃល្បោះ (Deciduous Forests = 619ហ.ត. = 12,73% នៃផ្ទៃដីគំរោងសរុប) ព្រៃផ្សេងៗ (Other Forests = 07ហ.ត. = 0,14% នៃផ្ទៃដីគំរោងសរុប) និងដីមិនមែនព្រៃ (Non-Forest = 1.158ហ.ត. = 23,82% នៃផ្ទៃដីគំរោងសរុប) (ការសិក្សាជាក់ស្តែង និងការពិគ្រោះយោបល់ជាសាធារណៈបានបង្ហាញឱ្យឃើញថា ភាគច្រើននៃព្រៃស្រោងនេះ គឺស្ថិតក្នុងស្ថានភាពជាព្រៃពាក់កណ្តាលស្រោងរេចរិល) ដែលក្នុងនោះរុក្ខជាតិដែលបានជួបប្រទះមានចំនួន67ប្រភេទ ហើយមាឌឈើឈរនៅក្នុងព្រៃពាក់កណ្តាលស្រោងនេះសរុបមានចំនួន201,65 $ម.^3$/ហ.ត.។ ទោះបីយ៉ាងណាភាគច្រើននៃឈើទាំងនេះមានគុណភាពពុំសូវសមស្រប សំរាប់ប្រើប្រាស់ជាឈើសំណង់ទេ

Draft

ដោយសារវាមាន លក្ខណៈប្រើការពុំសូវកើត (សភាពប្រហោងក្នុង កោងវៀច ដើមមិនត្រង់ និងខ្លះមានព្រឹងខ្ពស់) ហើយភាគច្រើន ជាប្រភេទឈើគុណភាព **b** និង **c** និងប្រភេទក្រៅលំដាប់ថ្នាក់។ វត្តមានសត្វលើគោក (ថនិកសត្វ ឧរង្គសត្វ និងសត្វ ស្លាប) និងសត្វក្នុងទឹក (មច្ឆាជាតិ) ដែលធ្លាប់មាន និងជួបប្រទះនៅក្នុងតំបន់គំរោងមានចំនួន 79ប្រភេទ ប៉ុន្តែសត្វ ទាំងអស់នេះពុំបានជួបប្រទះញឹកញាប់ ឬបាត់បង់ស្ទើរតែទាំងស្រុងទៅហើយនាពេលបច្ចុប្បន្ន។ ចំណែក ឯប្រព័ន្ធផ្លូវទឹក វិញមានមួយចំនួនដែរនៅក្នុងតំបន់គំរោង ប៉ុន្តែភាគច្រើនទទួលរងនូវការគោករាំងស្ងួត ជាពិសេស នៅរដូវប្រាំង។ អន្តរអំពើនៃធនធានទាំងនេះបង្កើតជាប្រព័ន្ធ អេកូឡូស៊ីសំខាន់មួយនៅក្នុងតំបន់នេះដែលជាប្រភពចំណី អាហារ ទឹក ផល-អនុផលព្រៃឈើ ឱសថ និងផ្តល់នូវសេវាកម្មផ្សេងៗទៀតដូចជា និយ័តកម្មទឹកជំនន់-អាកាសធាតុ បន្សុទ្ធទឹក-បរិយាកាស ការពារការហូរច្រោះដី ការផ្ទុក-ស្រូបកាបូន ព្រមទាំងផ្តល់នូវតំលៃវប្បធម៌ ការសិក្សាស្រាវ-ជ្រាវ និងទេសចរណ៍តំបន់ភូមិភាគឥសាន។ ទោះជាយ៉ាងនេះក្តី ផលិតផល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីទាំងនេះបាន នឹងកំពុងទទួលរងនូវការបំផ្លិចបំផ្លាញដោយសារសកម្មភាពរបស់មនុស្ស ជាពិសេសសកម្មភាពរានដីព្រៃធ្វើកម្មសិទ្ធិ (ស្រែ-ចំការពនេចរ) កាប់ឈើ និងចាប់សត្វជាដើម។ ប្រសិនបើពុំមានវិធានការដ៏មានប្រសិទ្ធិភាពទេនោះ សកម្មភាព បំផ្លិចបំផ្លាញទាំងនេះនឹងកាន់តែរីករាលដាលកាន់តែខ្លាំងឡើង និងអាចធ្វើឱ្យធនធានទាំងនេះបាត់បង់ទាំងស្រុងនាពេល អនាគតដោយមិនបានផ្តល់ផលប្រយោជន៍អ្វីដល់សង្គម និងចំណូលអ្វីដល់សេដ្ឋកិច្ចជាតិ។

ស្ថានភាពសេដ្ឋកិច្ច-សង្គមបានសិក្សាផ្តោតសំខាន់ទៅលើប្រជាសាស្ត្រ ការតាំងទីលំនៅ មុខរបរ ការប្រើប្រាស់ដីធ្លី ការប្រើប្រាស់ទឹក ការប្រើប្រាស់ថាមពលរបស់សហគមន៍មូលដ្ឋាន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គម ការអប់រំ សុខភាព និងសុខមាលភាពសាធារណៈ វប្បធម៌ និងទេសចរណ៍។ ភូមិដែលស្ថិតនៅក្នុងឃុំបួន (ឃុំកិចុង ឃុំកក់ ឃុំលំជ័រ និងឃុំសោមធំ) មានប្រជាពលរដ្ឋរស់នៅពាក់ព័ន្ធ និងនៅក្បែរទីតាំង គំរោងច្រើនជាងគេ គឺភូមិក្រៀល (773នាក់) ភូមិកាចក (487នាក់) ភូមិប្រឡេ (498នាក់) និងភូមិសោមគល់ (617នាក់)។ មុខរបរសំខាន់នៅក្នុងតំបន់នេះ គឺ ការធ្វើស្រែ-ចំការ និងដាំដំណាំ។ លើសពីនេះទៀត មុខរបរកាប់ឈើ បរបាញ់ រកវ័ល្លែង ប្រមូលអនុផលព្រៃឈើ និង សេវាកម្មផ្សេងៗទៀត ត្រូវបានប្រកបដោយប្រជាពលរដ្ឋភាគច្រើននៅក្នុងតំបន់នេះ។ ក្រៅពីផ្ទៃដីព្រៃឈើ សំណង់ លំនៅដ្ឋាន ប្រព័ន្ធស្រោចស្រព និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ការប្រើប្រាស់ដីនៅក្នុងឃុំទាំងនេះ គឺផ្តោតសំខាន់ទៅលើផ្ទៃ ដីកសិកម្ម (សរុបចំនួន14.049ហ.ត.)។ ផ្ទៃដីចំការដាំដុះជាក់ស្តែង យ៉ាងហោចណាស់ប្រមាណ149,40ហ.ត. របស់ ប្រជាពលរដ្ឋចំនួន28គ្រួសារ ស្ថិតនៅក្នុងទីតាំងគំរោង។ ទឹកប្រើប្រាស់សំរាប់ការធ្វើកសិកម្មមានប្រភពមកពីទឹកភ្លៀង ចំណែកឯទឹកប្រើប្រាស់នៅក្នុងលំនៅដ្ឋានមានប្រភពមកពីទឹកភ្លៀង ទឹកអូរ និងទឹកអណ្តូងផ្សេងៗ ជាពិសេសទឹកអណ្តូង ច្រប់។ ថាមពលប្រើប្រាស់សំរាប់ការបំភ្លឺមានប្រភពមកពីអាគុយ និងចង្កៀងប្រេងកាត ចំណែកឯថាមពលប្រើប្រាស់ សំរាប់ផ្គត់ផ្គង់ការចំអិនអាហារមានប្រភពទាំងស្រុងមកពីអុសដែលកាប់ពីព្រៃ។ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសង្គមមិនទាន់ មានការអភិវឌ្ឍន៍ខ្លាំងក្លានៅឡើយទេ។ ដោយឡែកប្រព័ន្ធអប់រំមានការអភិវឌ្ឍន៍មួយកំរិត ដោយមានសាលារៀន

Draft

និងគ្រូបង្រៀនដែលបានផ្ដល់ឱកាសឱ្យកូនចៅប្រជាពលរដ្ឋចូលរៀន ក្នុងកំរិតបឋមសិក្សារហូតដល់អនុវិទ្យាល័យ ។ សេវាកម្មសុខភាពមានការអភិវឌ្ឍន៍តិចតួចណាស់ដោយមានតែប៉ុស្ដិ៍សុខភាព ដែលស្ថិតនៅក្នុងទីរួមឃុំ-ស្រុកប៉ុណ្ណោះ ហើយជំងឺដែលកើតមានជាញឹកញាប់ គឺជំងឺគ្រុនចាញ់ គ្រុនឈាម គ្រុនផ្ដាសសាយ គ្រុនពោះវៀន និងជំងឺពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកដូចជា រាគរូសជាដើម ។ តំបន់គំរោងពុំមានវត្ថុមានសម្បត្តិវប្បធម៌សំខាន់ៗដែលគួរឱ្យកត់សំគាល់នោះទេ លើកលែងតែវត្តមានជនជាតិដើមភាគតិចទំពួន និងចារាយមួយចំនួនប៉ុណ្ណោះ ។ ទេសចរណ៍ធម្មជាតិ និងវប្បធម៌ ក៏មិនទាន់មានការអភិវឌ្ឍន៍នៅឡើយដែរ ។ ជារួម ការរស់នៅ និងជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ គឺមានលក្ខណៈជាស្ថានភាពសេដ្ឋកិច្ចជនបទ ដែលពឹងផ្អែកស្ទើរតែទាំងស្រុងលើធនធានធម្មជាតិ ។

## ៥. ការចូលរួមជាសាធារណៈ

ការស្ទង់មតិ ជួបប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញ អាជ្ញាធរ និងសហគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធ ដើម្បីប្រមូលនូវមតិសាធារណៈ និងស្វែងរកដំណោះស្រាយមួយដ៏ល្អ និងអាចទទួលយកបានសំរាប់ភាគីពាក់ព័ន្ធទាំងអស់អំពីបញ្ហាបរិស្ថាន និងសង្គម ដែលអាចបង្កឡើងដោយសារសកម្មភាពគំរោងធ្វើអាជីវកម្មរ៉ែដែករបស់ក្រុមហ៊ុន ។ លទ្ធផលបានបង្ហាញឱ្យឃើញថា ភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងកិច្ចពិគ្រោះយោបល់ មិនបានបង្ហាញនូវការជំទាស់ចំពោះវត្តមានគំរោងនេះទេ ព្រោះវាជាការសំរេចចិត្តរបស់រាជរដ្ឋាភិបាល (ប្រសិនបើទុកដីនេះចោលទំនេរវានឹងបាត់បង់ផលប្រយោជន៍ជាតិជាងការធ្វើវិនិយោគរបស់ក្រុមហ៊ុន) ប៉ុន្តែមានការបារម្ភ ជាពិសេសទៅលើការបាត់បង់ដីធ្លីសំរាប់ការដាំដំណាំ និងការបាត់បង់មុខរបររបស់ប្រជាពលរដ្ឋ និងធនធានព្រៃឈើ ។ ជាមួយគ្នានេះដែរ ពួកគាត់ក៏បានសុំសំណូមពរឱ្យរាជរដ្ឋាបាល ក៏ដូចក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនជួយធ្វើការផ្សព្វផ្សាយ និងពន្យល់អំពីគោលបំណង និងសារៈប្រយោជន៍គំរោងដល់ប្រជាពលរដ្ឋ ដោះស្រាយដីធ្លីដែលប៉ះពាល់ឱ្យបានសមរម្យ រកវិធីសាស្ត្រឈូសឆាយព្រៃទៅតាមបទដ្ឋានបច្ចេកទេសដែលបានកំនត់ដោយស្ថាប័នដែលពាក់ព័ន្ធ និងសហការឱ្យបានស្អិតរមួតជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធដើម្បីចៀសវាងនូវបញ្ហាសង្គមផ្សេងៗ ផ្ដល់អាទិភាពការងារដល់ប្រជាពលរដ្ឋមូលដ្ឋាន ធានាសុវត្ថិភាពការងារជូនបុគ្គលិក-កម្មករ ព្រមទាំងជួយចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានដូចជា ជួយអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ-សង្គមជូនសហគមន៍មូលដ្ឋាន ។ បន្ថែមពីនេះទៀត ក្រុមហ៊ុនត្រូវគោរពនូវកិច្ចសន្យា និងប្រតិបត្តិការងារនានារបស់ខ្លួនដូចជា ការឈូសឆាយដី ការសិក្សាស្រាវជ្រាវរុករករ៉ែ ការជីក យករ៉ែ ដំណើរការសាងសង់ និងការធ្វើសកម្មភាពអ្វីមួយឱ្យស្របទៅតាមប្លង់មេ និងបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់ ។

## ៦. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ធនធានជីវសាស្ត្រ រូបសាស្ត្រ និងសេដ្ឋកិច្ច-សង្គមដូចរៀបរាប់ខាងលើ នឹងអាចទទួលរងនូវការប៉ះពាល់ជាអវិជ្ជមាន ដោយសារសកម្មភាពគំរោងអភិវឌ្ឍន៍នេះ ។ នៅក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង ការប៉ះពាល់សំខាន់ៗរួមមាន: (i) ការបាត់បង់ព្រៃឈើប្រមាណ44,40ហ.ត. ដោយសារការឈូសសំអាតគំរបព្រៃសំរាប់ការសាងសង់ហេដ្ឋា-

រចនាសម្ព័ន្ធគំរោង និងទីតាំងជីកយកល្បាយអាចម៍រ៉ែ (ii) ការប៉ះពាល់ដោយផ្ទាល់ និងប្រយោលដល់សត្វព្រៃដោយសារបរបាញ់ពីសំណាក់បុគ្គលិក-កម្មករគំរោង និងការរំខានផ្សេងៗពីសកម្មភាពសាងសង់ (iii) ការធ្វើឱ្យខូចខាតប្រព័ន្ធផ្លូវទឹក និងគុណភាពទឹកដោយសារការហូរច្រោះអាចម៍ដី និងការទុកដាក់សំណល់គ្រប់ប្រភេទមិន[illegible]នត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស (iv) ការប៉ះពាល់ទៅដំណើរការដាំដុះដំណាំ និងស្រែ-ចំការរបស់ប្រជាពលរ[illegible] ដោយសារផ្ទៃដីដាំដុះទាំងនេះស្ថិតនៅក្នុងទីតាំងគំរោង និង (v) ការប៉ះពាល់ដល់មុខរបរកាប់ឈើ និងប្រមូលអ[illegible]ព្រៃឈើផ្សេងៗរបស់ប្រជាពលរដ្ឋដោយសារការហាមឃាត់មិនឱ្យពួកគាត់ចូលប្រកបមុខរបរ ឬប្រមូលអនុផល[illegible]ឈើនៅក្នុងព្រៃនៅក្នុងទីតាំងគំរោង ។

នៅក្នុងដំណាក់កាលប្រតិបត្តិគំរោង ការប៉ះពាល់សំខាន់ៗរួមមាន: (i) ការបាត់បង់ព្រៃឈើប្រមា[illegible]04ហ.ត. បន្ថែមដោយសារការឈូសសំអាតគំរបព្រៃសំរាប់ការធ្វើអាជីវកម្ម (ii) ការបាត់បង់សត្វព្រៃដោយ[illegible] បាត់បង់ទីជំរក ការបរបាញ់ពីសំណាក់បុគ្គលិក-កម្មករគំរោង និងការរំខានផ្សេងៗពីសកម្មភាពឈូសឆាយ ([illegible] [illegible]ារធ្វើឱ្យខូចខាតរចនាសម្ព័ន្ធ និងគុណភាពដីដោយសារការហូរច្រោះដីស្រទាប់លើ និងការបាត់បង់ដីជាតិដីដោ[illegible] ការជីកយកល្បាយអាចម៍រ៉ែ (iv) ការធ្វើឱ្យខូចខាតគុណភាពទឹកដោយសារការហូរនាំអាចម៍ដីចូលទៅក្នុងប្រព័[illegible] ក៏ដូចជាការទុកដាក់សំណល់ និងសារធាតុគីមីគ្រប់ប្រភេទមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស (v) [illegible]ាល់ទៅលើការប្រើប្រាស់ទឹក ពីព្រោះតំរូវការទឹកសំរាប់ប្រព័ន្ធស្រោចស្រព អាចធ្វើឱ្យខ្វះទឹកសំរាប់ការប្រើប្រា[illegible] ប្រជា-ពលរដ្ឋ (vi) ការបាត់បង់មុខរបររបស់ប្រជាពលរដ្ឋដោយសារការបាត់បង់ព្រៃឈើដែលជាប្រភពផ្ដល់នូវ[illegible] អនុផលព្រៃឈើផ្សេងៗ និងចំណីសំរាប់ការចិញ្ចឹមសត្វ (vii) ការប៉ះពាល់ដល់ប្រពៃណី-វប្បធម៌របស់ជនជា[illegible]ភាគតិចផ្សេងៗដោយសារលំហូរចូលនៃប្រពៃណី-វប្បធម៌ពីមជ្ឈដ្ឋានខាងក្រៅ (viii) សុខភាព និងសុវត្ថិភាពការងារដោយសារការកើតមានឡើងនូវជំងឺផ្សេងៗដែលពាក់ព័ន្ធភាពខ្វះអនាម័យ និងការប្រើប្រាស់ទឹកមិនស្អាត (iv) ការខូចខាតផ្លូវគមនាគមន៍ និងការកើនឡើងនូវគ្រោះថ្នាក់ចរាចរណ៍ ដោយសារការកើនឡើងនូវសកម្មភាពដឹកជញ្ជូនវត្ថុធាតុដើម និងផលិតផលចេញ-ចូលទីតាំងគំរោង និង (x) ការប៉ះពាល់ដល់សុខភាព និងសុខមាលភាពសាធារណៈដោយសារការថយចុះនូវគុណភាពទឹក-ខ្យល់ និងការរំខានដោយសំលេង-រំញ័រ ។ ជារួម សកម្មភាពគំរោងក្នុងដំណាក់-កាលប្រតិបត្តិនេះនឹងធ្វើឱ្យប្រែប្រួលស្ទើរតែទាំងស្រុងនូវផលិតផល និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នេះ ដែលមានទំនាស់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន ។

ការប៉ះពាល់បរិស្ថាន-សង្គមជាអវិជ្ជមានទាំងនេះអាចមានកំរិតធំជាងនេះ ប្រសិនបើពុំមានផែនការគ្រប់គ្រងបរិស្ថាន-សង្គមត្រឹមត្រូវទេនោះ ។ ផ្ទុយទៅវិញ ការប៉ះពាល់ទាំងនេះអាចកាត់បន្ថយបានមួយកំរិតទៀត តាមរយៈការអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន-សង្គម នៅក្នុងដំណាក់កាលមុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គំរោង ។

នៅក្នុងដំណាក់កាលមុនប្រតិបត្តិ ក្រុមហ៊ុននឹង: (i) ដោះស្រាយនូវការប៉ះពាល់ទៅលើដីធ្លីធ្វើស្រែ-ចំការ និងដំណាំរបស់ប្រជាពលរដ្ឋដោយសន្តិវិធី និងដោយលក្ខណៈល្អសមរម្យដែលអាចទទួលយកបានសំរាប់ភាគីទាំងអស់គ្នា (ធ្វើការប៉ះប៉ូវជាសំណងដោយផ្អែកទៅតាមទិន្នផលដំណាំនីមួយៗ និងចំពោះកំលាំងពលកម្មកាប់ភ្ការស្រែ-ចំការជាលក្ខណៈពនេចរ) (ii) ចៀសវាងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងការជីកយកល្បាយអាចម៍រ៉ែនៅក្នុងព្រៃទ្រនាប់

តាមដងអូរ (iii) ផ្សព្វផ្សាយ និងអប់រំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងហាមឃាត់ដាច់ខាតមិនឱ្យបុគ្គលិក-កម្មករមានការពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធានទាំងនេះ (iv) ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីគោលការណ៍ណែនាំបច្ចេកទេស នៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព (v) អនុញ្ញាតឱ្យប្រជាពលរដ្ឋចូលប្រមូលអនុផលព្រៃឈើនៅក្នុងទីតាំងគំរោង និង (vi) ផ្គត់ផ្គង់ទឹកស្អាត និងសាងសង់បង្គន់អនាម័យសំរាប់បុគ្គលិក-កម្មករប្រើប្រាស់។

នៅក្នុងដំណាក់កាលប្រតិបត្តិ ក្រុមហ៊ុននឹង: (i) ឈូសសំអាតគំរបព្រៃទៅតាមលទ្ធភាព និងទៅតាម ផែនការមេក្នុងឆ្នាំនីមួយៗ និងតាមបច្ចេកទេសត្រឹមត្រូវ ពោល គឺពុំត្រូវបន្សល់ទុកនូវផ្ទៃដីដែលឈូសសំអាតហើយឱ្យនៅទំនេរ ឬពន្យាពេលធ្វើអាជីវកម្ម (ii) ចៀសវាងការឈូសសំអាតគំរបព្រៃទ្រនាប់តាមដងអូរសំរាប់ការជីកយកល្បាយអាចម៍រ៉ែ (iii) ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីគោលការណ៍បច្ចេកទេសក្នុងការទុកដាក់ និងប្រើប្រាស់សារធាតុគីមី និងការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព (iv) ផ្សព្វផ្សាយ និងអប់រំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងហាមឃាត់ដាច់ខាតមិនឱ្យបុគ្គលិក-កម្មករមានការពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធានទាំងនេះ (v) រៀបចំកម្មវិធីធ្វើអនាម័យបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ/កន្លែងស្នាក់នៅ (vi) ផ្គត់ផ្គង់ទឹកស្អាត និងសាងសង់បង្គន់អនាម័យបន្ថែមសំរាប់បុគ្គលិក-កម្មករប្រើប្រាស់ (vii) ផ្តល់អាទិភាពទទួលបានការងារធ្វើដល់សហគមន៍មូលដ្ឋាន និង (viii) ផ្សព្វផ្សាយ និងអប់រំដល់បុគ្គលិក-កម្មករឱ្យចេះគោរពប្រពៃណី-វប្បធម៌ជនជាតិផ្សេងៗ។

ដើម្បីធានាឱ្យបាននូវការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន-សង្គម និងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ក្រុមហ៊ុនក៏នឹងបង្កើតមាននូវយន្តការត្រួតពិនិត្យ អង្កេតតាមដាន និងរាយការណ៍ពីលទ្ធផលនៃការអនុវត្តនេះផងដែរ។ លើសពីនេះទៀត ក្រុមហ៊ុននឹងសហការល្អជាមួយនឹងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន ក្នុងករណីដែលមានចុះអង្កេតតាមដានបន្ថែមនានា។ នៅពេលបញ្ចប់គំរោង ក្រុមហ៊ុននឹងរៀបចំផែនការបញ្ចប់គំរោង ដោយធ្វើការស្តារបរិស្ថានឡើងវិញ (ប្រគល់ដីស្រែ-ចំការជូនប្រជាពលរដ្ឋម្ចាស់ដើមវិញ ចាក់ដីបំពេញទីតាំងដែលជីកយកល្បាយអាចម៍រ៉ែរួច និងធ្វើការដាំដើមឈើឡើងវិញជាដើម) ព្រមទាំងកាលវិភាគសំរាប់បំពេញការងារទាំងនេះជារៀងរាល់ឆ្នាំ។

ទន្ទឹមនឹងការប៉ះពាល់អវិជ្ជមាន គំរោងនេះក៏នឹងនាំមកនូវផលប្រយោជន៍ជាច្រើនដល់សង្គមជាតិដូចជា បង្កើនប្រាក់ចំណូលជាតិ (ដោយសារការជួលដី និងប្រមូលសួយសារ និង បុព្វលាភលើផលរ៉ែពីការធ្វើអាជីវកម្ម និង និងការកាប់ឈើ) និងចូលរួមជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ផ្តល់មុខរបរ និងប្រាក់ចំណូលជូនប្រជាពលរដ្ឋកម្ពុជាជាច្រើននាក់ ជាពិសេសប្រជាពលរដ្ឋមូលដ្ឋាន។ លើសពីនេះទៀត គំរោងក៏អាចជួយថែរក្សា និងការពារធនធានព្រៃឈើល្អៗ (ព្រៃទ្រនាប់តាមដងអូរ) ក្នុងផ្ទៃដីទំហំ400ហ.ត. ឱ្យនៅគង់វង្សសំរាប់ជាប្រយោជន៍ដល់សហគមន៍មូលដ្ឋាន និងមនុស្សជាតិទូទៅ។

## ៧. ផែនការគ្រប់គ្រងបរិស្ថាន

បន្ថែមពីលើនេះទៀត ក្រុមហ៊ុនបានរៀបចំឡើងនូវផែនការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន (ការស្តារព្រៃឈើឡើងវិញ ការជំរុញការចិញ្ចឹមសត្វស្រុក និងសត្វត្រី ការជួសជុលផ្លូវលំ ផ្តល់សេវាកម្មបច្ចេកទេសផ្នែកដាំដំណាំកៅស៊ូ ដំឡូងមី និងផ្តល់សេវាកម្មផ្នែកទីប្រឹក្សាសំរាប់ការដាំដុះដំណាំផ្សេងៗ) ដែលជំនួយមូលនិធិសង្គមទាំងនេះនឹងចំណាយថវិកាសរុបចំនួន892.000ដុល្លាអាមេរិក ក្នុងរយៈពេល10ឆ្នាំ។ ចំណែកឯថវិកាសំរាប់ស្តារបរិស្ថានឡើងវិញមានចំនួន180.794ដុល្លាអាមេរិក/ឆ្នាំ។

## ៨.សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជាសរុប ទោះបីជាមានការប៉ះពាល់អវិជ្ជមាននៅសេសសល់ បន្ទាប់ពីការអនុវត្តនូវវិធានការកាត់បន្ថយ និងផែនការគ្រប់គ្រងបរិស្ថានក៏ដោយ ក៏វត្តមានគំរោងអភិវឌ្ឍន៍ធ្វើអាជីវកម្មរ៉ែដែកនេះនឹងផ្តល់នូវផលប្រយោជន៍ដល់សង្គមជាតិច្រើនជាងការទុកទីតាំងនេះឱ្យស្ថិតនៅក្នុងស្ថានភាពបំផ្លិចបំផ្លាញដូចក្នុងពេលបច្ចុប្បន្ន។

ជាអនុសាសន៍ ក្រុមហ៊ុននឹងទទួលគោរព និងអនុវត្តឱ្យបាននូវផែនការគ្រប់គ្រងបរិស្ថាន និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននេះឱ្យមានប្រសិទ្ធិភាព ដោយមានការចូលរួមត្រួតពិនិត្យបន្ថែមពីក្រសួងបរិស្ថាន ក្រសួង/ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្តរតនគិរី។

Draft